**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

/ល

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ២.០០០ លានរៀល ( ពីរពាន់លានរៀលគត់ ) ពីជំពូក ០៩ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ ( ការទិញ ) ជូនព្រឹទ្ធសភា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទិញរថយន្តម៉ាក Toyota Land Cruiser ជូនថ្វាយ សម្តេច ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំព្រឹទ្ធសភា និង សំរាប់ទិញរថយន្តម៉ាក Toyota ១២ កៅអី ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្តេចប្រធានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត់ ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ